# ថ្នាំគ្រុនផ្តាសាយធម្មតាអាចមានគ្រោះថ្នាក់ដល់ក្មេងក្រោមអាយុ 2 ឆ្នាំ

Cold Meds Not Safe for Kids Under 2, FDA Warns

WUML

1/20/08

ក្រសួងរដ្ឋបាលនៃសហរដ្ឋ ទទួលបន្ទុកខាងផ្នែកម្ហូបអាហារនិងថ្នាំសង្កូវ, U.S. Food and Drug Administration ឬ ក្រសួង FDA បានប្រកាសកាលពីថ្ងៃព្រហស្បតិ៍ ទី17 ខែមករា កន្លងមកនេះថា សាធារណៈជន គួរកុំឲ្យថ្នាំក្អកនិងថ្នាំគ្រុនផ្តាសាយ ដែលទិញដោយពុំបាច់មានសំបុត្រពីគ្រូពេទ្យ ដល់ក្មេងដែលមានអាយុតិចជាង 2 ឆ្នាំឲ្យសោះ។

ទោះបីជាមានការផ្សាយដំណឹងអំពីគ្រោះថ្នាក់ ក្នុងការប្រើថ្នាំសំរាប់ក្មេងតូចៗ ក្នុងពេលថ្មីនេះយ៉ាងណា ក៏ដោយ ក៏ក្រសួង FDA នៅតែបារម្ភថា សាធាណៈជននៅតែពុំបានចាប់អារម្មណ៍ពីបញ្ហានេះ ដដែល។

វេជ្ជបណ្ឌិត Charles Ganley នាយក នៃក្រសួង FDA ការិយាល័យផ្នែក ថ្នាំទិញដោយពុំបាច់មានសំបុត្រពីគ្រូពេទ្យ មានប្រសាសន៍ នៅពេលផ្សាយដំណឹងនេះថា មាតាបិតាពុំគួរឲ្យថ្នាំក្អក និងថ្នាំគ្រុនផ្តាសាយ ដល់ក្មេងដែលមានអាយុតិចជាង 2 ឆ្នាំនោះឡើយ។ ពីព្រោះ ថ្នាំទាំងនេះ អាចបណ្តាលឲ្យមានជាផលវិបត្តិ ឬគ្រោះថ្នាក់ដល់ជីវិត ដល់ក្មេងទាំងនោះបាន។ ការិយាល័យរបស់លោក នៅពុំទាន់សំរេច ចេញបញ្ញត្តិឲ្យក្មេងអាយុពី 2 ឆ្នាំ ទៅ 11 ឆ្នាំលេបថ្នាំទាំងនេះនៅឡើយទេ។ លោកកំពុងធ្វើការយ៉ាងសកម្មជាមួយការិយាល័យឯទៀតរបស់ក្រសួង FDA ដើម្បីធ្វើការសំរេចចិត្តនេះ។

អ្នកស្រីវេជ្ជបណ្ឌិត Catherine Tom-Rezon អ្នកចាត់ការនៅឧសុថស្ថាន នៃមន្ទីរពេទ្យ កុមារ Montefiore Medical Center នៅទីក្រុង នូវយ៉ក មានប្រសាសន៍ថា ការផ្សាយដំណឹងពីក្រសួង FDA ជាការមួយយ៉ាងល្អ។  គ្រូពេទ្យជាច្រើន ព្រមទាំងអ្នកស្រីផង តែងតែងជៀសវាងពុំសរសេរសំបុត្រទិញថ្នាំសំរាប់ក្មេងតូចៗ ប្រើឡើយ នៅពេលគាត់ពុំទាន់មានសេចក្តី បញ្ជាក់ពីការស្រាវជ្រាវណាមួយ ឲ្យបានច្បាស់លាស់នោះឡើយ។

កាលពីខែ វិច្ឆិកាកន្លងមកនេះ ក្រសួង FDA បានទទួលលទ្ធផលពីការស្ទង់មតិមួយចំនួន ដែលគួរឲ្យបារម្ភថា មាតាបិតានៅតែឲ្យថ្នាំទាំងនេះទៅកូនរបស់ខ្លួនលេប ដោយពុំមានការពិភាក្សាជាមួយគ្រូពេទ្យរបស់កូនឡើយ។

ថ្នាំគ្រុនផ្តាសាយនិងថ្នាំក្អកទាំងនេះ មានទាក់ទងទៅនឹងបញ្ហាសុខភាពរបស់ក្មេងតូចៗ ដោយរួមទាំង ការប្រកាច់ ដោយសារការក្តៅខ្លួនខ្លាំងពេក (Convulsion), ធ្វើឲ្យបេះដូងដើរញាប់ខុសធម្មតា, ក្មេងបាត់ស្មារតីពុំដឹងខ្លួន និងរហូតដល់ស្លាប់បាត់បង់ជីវិត ក៏មាន។

សំណុំរឿងដែលបានរាយការណ៍ទៅ ក្រសួង FDA នៅចន្លោះពីឆ្នាំ 1969 ដល់ខែ កញ្ញា ឆ្នាំ 2006 បញ្ជាក់ឲ្យដឹងថា មានក្មេងចំនួន 54 នាក់ស្លាប់ដោយសារបញ្ហាសុខភាពទាក់ទងនឹងថ្នាំគ្រុនផ្តាសាយដែលធ្វើពីជាតិ pseudoephedrine, phenylephrine, ឬ ephedrine។ ជាមួយគ្នានេះ មានក្មេងចំនួន 69 នាក់ទៀត ស្លាប់ ដោយសារបញ្ហាសុខភាពទាក់ទងទៅនឹងថ្នាំ ក្អកដែលមានជាតិ diphenhydramine, brompheniramine, ឬ chlorpheniramine។ ក្មេងដែលស្លាប់ទាំងនោះ ភាគច្រើន មានអាយុតិចជាង 2 ឆ្នាំ។

សេចក្តីប្រកាសនេះ គឺពឹងផ្អែកទៅលើការពិនិត្យទិន្នន័យ (data) នៃក្រសួង FDA និងការពិភាក្សាក្នុងអង្គប្រជុំរវាង ក្រុមប្រឹក្សាផ្នែកថ្នាំទិញដោយពុំបាច់មានបញ្ជាពីគ្រូពេទ្យ (Nonprescription Drug) និងពេទ្យកុមារ កាលពីខែ តុលាកន្លងមកនេះ។

មុនពេលប្រជុំនេះ ក្រុមហ៊ុនធ្វើថ្នាំគ្រុនផ្តាសាយនិងថ្នាំក្អកដែលសំរាប់ឲ្យក្មេងតូចៗប្រើ បានស្ម័គ្រចិត្ត ប្រមូលថ្នាំទាំងនោះទុកវិញ។ ជាពិសេស គឺ ថ្នាំដែលមានដាក់រូបក្មេងតូចៗនៅលើដប និងថ្នាំដែលមានដាក់អក្សរថាសំរាប់ក្មេងតូចៗប្រើ។ ជាទូទៅ នៅសហរដ្ឋមានលក់ថ្នាំគ្រុនផ្តាសាយឬថ្នាំក្អកចំនួនប្រហែលជា 800 មុខ។ អ្នកជំនាញការបានប៉ាន់ស្មានថាប្រជាជនក្នុងសហរដ្ឋបាន ចំណាយប្រាក់យ៉ាងហោចណាស់ ចំនួន 2 រយកោដិ ឬ 2 Billion dollar សំរាប់ទិញថ្នាំប្រភេទនេះ ក្នុងមួយឆ្នាំៗ

អ្នកស្រី Lisa Mathis នាយករងនៃ ក្រសួង FDA ការិយាល័យផ្នែកឧសថចេញថ្មីៗ, ពេទ្យកុមារ, និងសុខភាពម្តាយ បានផ្តល់យោបល់ដល់អ្នកដែលមានកូនអាយុតិចជាង 2 ឆ្នាំ ថា៖

- គួរចាំជានិច្ចថា ថ្នាំទាំងនេះពុំអាចព្យាបាលរោគគ្រុនផ្តាសាយ ឲ្យបានដាច់ជាស្រឡះនោះឡើយ គឺវាគ្រាន់តែជួយបំបាត់អាការៈដែលបណ្តាលមកពីរោគគ្រុនផ្តាសាយនោះប៉ុណ្ណោះ។
- ប្រសិនបើលោកអ្នកសំរេចឲ្យថ្នាំកូនលេប សូមអានបញ្ជីគ្រឿងឬជាតិថ្នាំ ដែលមាននៅលើផ្លាករបស់ដបថ្នាំទាំងនោះ ដើម្បីឲ្យដឹងថា តើគ្រឿងទាំងនោះជួយអ្វីខ្លះ។
- សូមប្រយ័ត្ន ឲ្យមែនទែន នៅពេលណាឲ្យថ្នាំគ្រុនផ្តាសាយ ឬថ្នាំក្អក ដែលទិញដោយពុំបាច់មានសំបុត្រពីគ្រូពេទ្យ, Over the Counter, កូនពីរមុខលាយគ្នា។ សូមមេត្តាចាំថា

ថ្នាំទាំងនេះ អាចមានគ្រឿងច្រើនក្នុងនោះ។ ប្រសិនបើលោកអ្នកឲ្យថ្នាំកូនពីរមុខ លាយគ្នា វាអាចមានកម្លាំងខ្លាំង ហួសកំរិតសំរាប់កូនតូច។

- សូមឲ្យកូនលេបទៅតាមសេចក្តីណែនាំនៅលើដកនោះ។
- សូមប្រើតែប្រដាប់បន្តក់ ឬពែងដែលមានជាប់មកជាមួយនឹងដបថ្នាំទាំងនេះ គឺកុំយកប្រដាប់វាល់ផ្សេងៗ ដែលមាននៅក្នុងផ្ទះស្រាប់ ទៅប្រើឲ្យសោះ។
- ប្រសិនបើលោកអ្នក អាចប្រើដបថ្នាំដែលមានប្រដាប់កាពារ ដើម្បីកុំឲ្យក្មេងបើកគម្របខ្លួនឯងបាននោះ វាជាការប្រសើរ។
- សូមដាក់ដបថ្នាំ ឲ្យខ្ពស់ឆ្ងាយពីដៃក្មេង។
- សូមពិភាក្សាជាមួយគ្រូពេទ្យ, អ្នកលក់ថ្នាំ, ឬបុគ្គលិកសុខាភិបាល ប្រសិនបើ លោកអ្នកមានសំណួរអ្វីផ្សេងៗ អំពីវិធីប្រើថ្នាំដែលត្រូវឲ្យកូនអាយុក្រោម 2 ឆ្នាំលេប។

ចំពោះពត៌មានបន្ថែមស្តីអំពីការប្រើថ្នាំគ្រុនផ្តាសាយនិងថ្នាំក្អកសំរាប់ក្មេងអាយុក្រោម 2ឆ្នាំ សូមមេត្តាអានវិបសៃរបស់ ក្រសួងរដ្ឋបាលសហរដ្ឋទទួលបន្ទុកផ្នែកខាងម្ហូបអាហារនិងថ្នាំសង្កូវ, U.S. Food and Drug Administration ដែលមានអាសយដ្ឋាន www.fda.gov .

Soutrce: www.healthfinder.gov